# 2 វិធីបង្ការកុំឲ្យមានផ្ទៃពោះ : ស្រោមអនាម័យ និង ស្រោម Diagphragms

# (2. Contraception: Condoms & Diagphragms)

## ហេតុអ្វីបានជាប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ?

**ការបង្ការមិនឲ្យមានផ្ទៃពោះ គឺជាការចាំបាច់ បើអ្នកចង់ចៀសវាងផ្ទៃពោះដែលមិនចង់បាន និងជំងឺកាមរោគ។**

រៀងរាល់ខែ អូវែររបស់ស្ត្រីផលិតពងមេជីវិតស្ត្រី។ នៅពេលដែលបុរសបញ្ចេញទឹកកាម ទឹកកាមនេះមានមេជីវិតបុរសរាប់លាន។ វាត្រូវការតែមេជីវិតបុរសនេះមួយប៉ុណ្ណោះ ដើម្បីចូលទៅបង្កាត់ក្នុងពងមេជីវិតស្ត្រី ហើយចាប់ផ្តើមមានផ្ទៃពោះ។ បើគូស្រករធ្វើការរួមរ័កនឹងគ្នា (លិង្គនៅក្នុងរន្ធយោនី) ហើយគ្មានការប្រុងប្រយ័ត្នជាមុនទេនោះ ស្ត្រីមានលទ្ធភាពខ្ពស់ក្នុងការមានផ្ទៃពោះ។ ការប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ អនុញ្ញាតឲ្យអ្នករួមរ័ក ហើយចៀសវាងការមានផ្ទៃពោះដោយអចេតនា។

### ស្រោមអនាម័យ មិនមែនជាគំនិតល្អជានិច្ចឡើយ

ប្រទេសអូស្ត្រាលី មានជំងឺកាមរោគថ្មីជាង 20 000 ក្នុងមួយឆ្នាំៗ។ ជំងឺកាមរោគទូទៅបំផុតគឺ chlamydia ដែលអាចធ្វើឲ្យមិនអាចមានកូនបាន បើទុកចោលមិនព្យាបាលទេនោះ។ ស្រោមអនាម័យគឺជាការការពារប្រសើរ បំផុតរបស់អ្នកទល់នឹងជំងឺកាមរោគ។ បើអ្នកប្រើស្រោមអនាម័យនិងប្រេងរំអិលធ្វើពីជាតិទឹក នៅរាល់ពេលដែលអ្នករួមភេទ អ្នកនឹងមានឱកាសតិចក្នុងការឆ្លង HIV/AIDS និងជំងឺកាមរោគ (STIs) ជាច្រើនទៀត។

## ស្រោមអនាម័យ

### ស្រោមអនាម័យរបស់ស្ត្រី

ស្រោមអនាម័យរបស់ស្ត្រី គឺជាបន្ទះស្រោមមានលាបប្រេងរំអិលជាមុន ដែលដាក់ចូលយ៉ាងធូររលុងទៅខាងក្នុងរន្ធយោនី។ កងទន់ដែលអាចដកយកចេញបាន ជួយស៊កស្រោមនេះ ព្រមទាំងរក្សាស្រោមនេះឲ្យនៅនឹងកន្លែង។ កងធំមួយដែលអាចបត់បែនបាន ស្ថិតនៅខាងក្រៅរន្ធយោនី ដោយគ្របផ្លូវបើករបស់រន្ធយោនី និង ផ្តល់កិច្ចការពារបន្ថែម។

ស្រោមអនាម័យរបស់ស្ត្រី មានប្រសិទ្ធភាពណាស់នៅពេលប្រើត្រឹមត្រូវ។ នេះមានន័យថា អ្នកត្រូវប្រើស្រោមថ្មី នៅរាល់ពេលដែលអ្នករួមរ័ក។ ស្រោមនេះធ្វើអំពីជាតិ polyurethane ហើយមានលាបប្រេងរំអិលជាមុន ដោយប្រើប្រេងរំអិលធ្វើពីជាតិស៊ីលីកូន។ ប្រេងរំអិលធ្វើពីជាតិប្រេង អាចប្រើជាមួយស្រោមអនាម័យស្ត្រី។ ស្រោមអនាម័យ គឺសំរាប់ប្រើតែម្តងប៉ុណ្ណោះ។ អ្នកមិនអាចស្រោមអនាម័យស្ត្រីជាមួយនឹងស្រោមអនាម័យបុរសឡើយ ដោយសារតែវាអាចបណ្តាលឲ្យរអិលចេញពីកន្លែងដាក់។

### ផលវិបាក

គ្មានទេ  លុះត្រាតែអ្នកមានប្រតិកម្មទៅនឹងជាតិ polyurethane ឬប្រេងរំអិល។ ហេតុការណ៍នេះកំរកើតមានណាស់។

### គុណសម្បត្តិ

- ➢ អាចស៊កបញ្ចូលមុនពេលរួមភេទ  ហើយមិនចាំបាច់ដកវាចេញជាបន្ទាន់ នៅបន្ទាប់ពីការរួមភេទឡើយ
- ➢ កាត់បន្ថយលទ្ធភាពនៃការមានផ្ទៃពោះ និង ជំងឺកាមរោគ
- ➢ មិនចាំបាច់ទៅជួបវេជ្ជបណ្ឌិត ដើម្បីសុំវេជ្ជបញ្ជាទេ។

## ស្រោមអនាម័យបុរស

ស្រោមអនាម័យបុរសគឺជាស្រោមកៅស៊ូស្តើង (latex) ឬ ជាតិ polyurethane ដែលពាក់នៅលើលិង្គឡើងរឹង។ ស្រោមនេះប្រមូលយកទឹកកាម ហើយបញ្ឈប់មិនឲ្យវាចូលទៅក្នុងរន្ធយោនីនិងស្បូន។

### តើវាមានប្រសិទ្ធភាពយ៉ាងណាដែរ?

បើប្រើត្រឹមត្រូវ ស្រោមអនាម័យមានប្រសិទ្ធភាព 85 ភាគរយ។ ស្រោមនេះគ្មានប្រសិទ្ធភាពដូចជា Pill (ថ្នាំគ្រាប់), IUD (ឧបករណ៍ដាក់ក្នុងស្បូន), DMPA (ថ្នាំ Depo Provera ឬ Depo Ralovera) ឬការវះស្បែកដាក់ថ្នាំបង្ការកុំឲ្យមានកូនឡើយ។

អ្នកត្រូវប្រើស្រោមថ្មីមួយនៅរាល់ពេលដែលអ្នករួមភេទ  ហើយប្រុងប្រយ័ត្នក្នុងការដាក់និងដកចេញឲ្យបានត្រឹមត្រូវ។ អ្នកគួរប្រើប្រេងរំអិលធ្វើពីជាតិទឹក ដូចជា  KY Jelly ឬ Wet Stuff នៅគ្រប់ពេលដែលអ្នកប្រើស្រោមអនាម័យ  ដោយសារតែប្រេងនេះកាត់បន្ថយលទ្ធភាពកុំឲ្យស្រោមរហែក។ ស្រោមអនាម័យគឺសំរាប់ប្រើតែម្តងគត់ប៉ុណ្ណោះ។

### ផលវិបាក

គ្មានទេ  លុះត្រាតែអ្នកឬគូកំណាន់អ្នក មានប្រតិកម្មទំនាស់ទៅនឹងកៅស៊ូ latex ឬ ប្រេងរំអិល។ ប្រតិកម្មទំនាស់ ទៅនឹងស្រោមធ្វើពីជាតិ polyurethane កំរកើតមានណាស់។

### គុណសម្បត្តិ

- ➢ កាត់បន្ថយលទ្ធភាពនៃការមានផ្ទៃពោះ និង ជំងឺកាមរោគ (STIs) ដោយមានរួមទាំង HIV/AIDS
- ➢ មិនចាំបាច់ទៅជួបវេជ្ជបណ្ឌិត ដើម្បីសុំវេជ្ជបញ្ជាទេ។

### គុណវិបត្តិ

សារធាតុដែលប្រើនៅក្នុងស្រោមអនាម័យបុរស អាចខូចដាច់រហែកបាន  ដូច្នេះអ្នកត្រូវទុកដាក់វានៅក្នុងកន្លែងត្រជាក់ ហើយប្រើមុនថ្ងៃផុតកាលកំណត់ឲ្យប្រើ។ អ្នកមិនគួរប្រើប្រេងរំអិលធ្វើពីជាតិប្រេង ដូចជាប្រេង petroleum jelly និងប្រេងធ្វើសរសៃ ជាមួយនឹងស្រោមអនាម័យធ្វើពីកៅស៊ូ latex ទេ  ដោយសារតែផលិតផលទាំងនេះបង្កើនលទ្ធភាពធ្វើឲ្យស្រោមដាច់រហែកបាន។ ប្រេងរំអិលទាំងនេះមានសុវត្ថិភាពក្នុងការប្រើ ជាមួយស្រោមអនាម័យជាតិ polyurethane ។

### ស្រោម Diaphragms

នេះជាគំរបកៅស៊ូទន់ ដែលពាក់ដាក់នៅខាងក្នុងរន្ធយោនី ដើម្បីគ្របកស្បូន (ផ្លូវចូលទៅក្នុងស្បូន)។ ស្រោមគំរបនេះបង្ការកុំឲ្យមេជីវិតបុរសចូលទៅក្នុងស្បូន។

### របៀបដែលស្រោមនេះមានប្រសិទ្ធភាព

ដើម្បីឲ្យស្រោម diaphragm មានប្រសិទ្ធភាព គេត្រូវដាក់វាឲ្យសមរម្យ ដាក់ឲ្យត្រឹមត្រូវ ហើយប្រើវានៅរាល់ពេលដែលអ្នករួមភេទ។ ស្រោមគំរបនេះមានប្រសិទ្ធភាពប្រហែលគ្នានឹងការប្រើស្រោមអនាម័យដែរ។

### គុណសម្បត្តិ

- ប្រើតែនៅពេលដែលអ្នករួមភេទប៉ុណ្ណោះ ហើយមិនប៉ះពាល់ដល់រាងកាយ នៅពេលផ្សេងទៀតឡើយ
- អាចប្រើនៅពេលដែលស្ត្រីកំពុងមានរដូវ
- អាចលាងសម្អាត ហើយប្រើសាជាថ្មីបាន ដោយអាចប្រើបានពីមួយឆ្នាំទៅពីរឆ្នាំ។

### គុណវិបត្តិ

- អ្នកត្រូវដាក់វាមុនពេលរួមភេទ (អ្នកអាចស៊កដាក់វា នៅពេលដល់ទៅ 24 ម៉ោងជាមុន) ហើយដក វាចេញ នៅពេលប្រាំមួយម៉ោងក្រោយមក
- ស្ត្រីខ្លះអាចយល់ថា គេមានការលំបាកនឹងស៊កដាក់វា
- មនុស្សមួយចំនួនតូច មានប្រតិកម្មទៅនឹងកៅស៊ូ។

## ទីកន្លែងទទួលពត៌មានបន្ថែម

**Women’s Health Information Centre (RWH)**
(03) 8345 3045
1800 442 007 (ទូរស័ព្ទឥតគិតថ្លៃ) អ៊ីមែល : whic@thewomens.org.au
http://wwww.thewomens.org.au

**The Choices Clinic នៅឯ Royal Women's Hospital**
ជាកិច្ចបំរើគិតថ្លៃថោក ដែលផ្តល់ឱវាទ ការពិគ្រោះឱវាទ និង ការព្យាបាលសំរាប់តម្រូវការបង្ការកុំឲ្យមានផ្ទៃពោះ និងសុខភាពផ្លូវភេទទាំងអស់។
ពេលម៉ោង : ថ្ងៃច័ន្ទ អង្គារ ព្រហស្បតិ៍ ម៉ោង 8.30 ព្រឹក ដល់ម៉ោង 11.30 ព្រឹក។
ទូរស័ព្ទ : (03) 8345 2000

## ប័ណ្ណពត៌មានឯទៀតដែលអាចមានប្រយោជន៍សំរាប់អ្នក

RWH មានប័ណ្ណពត៌មានផ្សេងៗជាភាសាច្រើន នៅតាមអ៊ីនធើរណិត។ បើអ្នកចង់បានពត៌មានបន្ថែម អ្នកអាចបើកមើលវ៉ិបសៃផ្សព្វផ្សាយសុខភាពរបស់យើង។ អាសយដ្ឋានគឺ :
http://www.thewomens.org.au

ឬអ្នកក៏អាចសុំឲ្យអ្នកថែទាំអ្នកនៅ RWH ផ្តល់ឲ្យអ្នកនូវឯកសារបោះផ្សាយ ឬ ប័ណ្ណពត៌មានណាមួយ នៃប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះផ្សេងទៀតរបស់យើងផងដែរ។ សូមសួររក :

ទី 1 វិធីបង្ការកុំឲ្យមានផ្ទៃពោះ : ជំរើសរបស់លោកអ្នក

ទី 3 Pill (ថ្នាំគ្រាប់)

ទី 4 Depo Provera - ការចាក់ថ្នាំបង្ការកុំឲ្យមានផ្ទៃពោះ

ទី 5 Implanon - ការវះផ្សាំបង្ការកុំឲ្យមានផ្ទៃពោះ

ទី 6 Intra Uterine Device (IUD)- (ឧបករណ៍ដាក់ក្នុងស្បូន)

**ពត៌មាននៅក្នុងប័ណ្ណពត៌មាននេះ គឺផ្អែកទៅលើប័ណ្ណពត៌មាន *Basic Facts About Contraception* (ហេតុការណ៍គោលការណ៍អំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះ) ដែលផលិតដោយ FPA Health**

មិនត្រូវផលិតឡើងវិញសំរាប់គោលបំណងលក់ដូរ ដោយគ្មានការអនុញ្ញាតរបស់ FPA Health និង Royal Womenís Hospital ឡើយ។

FPA health
Leading the way in reproductive & sexual health